# ផែនការ ក្រុមហ៊ុនធានារ៉ាប់រងភីងអាន អិលធីឌី ស្តីពីការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រសម្រាប់ប្រជាជនដែលមកប្រទេសចិន

**លក្ខខណ្ឌធានារ៉ាប់រង**

និស្សិតបរទេស និស្សិតហុងកុង ម៉ាកាវ និងតៃវ៉ាន់ រួមទាំងនិស្សិតចិននៅបរទេស (អត្តសញ្ញាណជនជាតិចិននៅក្រៅប្រទេសត្រូវតែបញ្ជាក់ដោយអង្គភាពពាក់ព័ន្ធ) ។ អ្នកដែលមានសុខភាពល្អ ហើយអាចចូលរួមក្នុងការសិក្សាជាធម្មតា ចាប់ពីអាយុ 8-69 ឆ្នាំ អាចចូលរួមក្នុងសេវាធានារ៉ាប់រងនេះបាន។

**កាតព្វកិច្ចធានារ៉ាប់រង**

ក្នុងកំឡុងពេលធានារ៉ាប់រង**(រយៈពេលគិតចាប់ពីកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងនេះរហូតដល់ថ្ងៃផុតកំណត់)** ក្រុមហ៊ុនមានកាតព្វកិច្ចធានារ៉ាប់រងដូចខាងក្រោម:

**1. ទំនួលខុសត្រូវក្នុងការធានារ៉ាប់រងមរណភាព៖**

ប្រសិនបើអ្នកធានារ៉ាប់រងបានស្លាប់ដោយសារគ្រោះថ្នាក់ឬជំងឺ ក្រុមហ៊ុននឹងបង់ថ្លៃធានារ៉ាប់រងតាមចំនួនទឹកប្រាក់ធានារ៉ាប់រងដែលបានព្រមព្រៀង ហើយការធានារ៉ាប់រងនឹងត្រូវបញ្ចប់។

**2. ទំនួលខុសត្រូវក្នុងការធានារ៉ាប់រងចំពោះពិការភាពដោយគ្រោះថ្នាក់ចៃដន្យ៖**

ក្នុងករណីអ្នកទទួលសេវាធានារ៉ាប់រងរងគ្រោះថ្នាក់ **ហើយក្នុងរយៈពេល 180 ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុដែលឈានទៅដល់ពិការភាព យោងតាម"បទដ្ឋានស្តង់ដារនិងកូដវាយតម្លៃពិការភាពនៃការធានារ៉ាប់រងអាយុជីវិត" (JR/T0083-2013) (ចេញដំបូងដោយគណៈកម្មាធិការគ្រប់គ្រងធានារ៉ាប់រងចិន [ឆ្នាំ 2014] លេខ 6)** ក្រុមហ៊ុនវាយតម្លៃពិការភាពដោយស្របតាមគោលការណ៍វាយតម្លៃដែលមានចែងជាធរមាន។ ក្នុងករណីពុំមានកិច្ចព្រមព្រៀងណាមួយ ចំពោះពិការភាពដោយគ្រោះថ្នាក់ចៃដន្យ **ក្រុមហ៊ុនបង់ថ្លៃធានារ៉ាប់រងដោយយកសមាមាត្រតំលៃទឹកប្រាក់ដែលត្រូវគ្នានឹងលទ្ធផលវាយតម្លៃមានចែងក្នុងគោលការណ៍ស្តង់ដារគុណនឹងចំនួនទឹកប្រាក់ធានារ៉ាប់រងដែលត្រូវបង់ជូនចំពោះពិការភាពដោយគ្រោះថ្នាក់ចៃដន្យ។**

ប្រសិនបើការព្យាបាលនៅមិនបានបញ្ចប់ ត្រូវធ្វើការវាយតំលៃលើពិការភាពដែលស្របតាមស្ថានភាពកាយសម្បទាជាក់ស្តែងនៅថ្ងៃទី 180 គិតចាប់ពីថ្ងៃកើតហេតុ ហើយការបង់ប្រាក់ធានារ៉ាប់រងពិការភាពដោយគ្រោះថ្នាក់ចៃដន្យនឹងត្រូវបង់ទៅតាមលទ្ធផលវាយតំលៃដែលទទួលបាន។

ក្នុងករណីពិការភាពរបស់អ្នកទទួលសេវាធានារ៉ាប់រងដែលបណ្តាលមកពីគ្រោះថ្នាក់រួមផ្សំនឹងពិការភាពពីមុន យោងតាម"ស្តង់ដារវង្វាយតម្លៃពិការភាពសម្រាប់ការធានារ៉ាប់រងអាយុជីវិត" អាចត្រូវបានវាយតម្លៃថាជាករណីធ្ងន់ធ្ងរ ក្រុមហ៊ុននឹងទូទាត់តាមលក្ខខណ្ឌស្តង់ដារសម្រាប់ករណីធ្ងន់ធ្ងរ **ប៉ុន្តែប្រសិនត្រូវបានបង់រួចរាល់នៅក្នុងគ្រោះថ្នាក់ពីមុននឹងត្រូវបានកាត់ចេញ (ប្រសិនមានមុនការធានារ៉ាប់រងឬដោយសារករណីលើកលែងមិនរាប់បញ្ចូល តាម"បទដ្ឋានស្តង់ដារនិងកូដវាយតម្លៃពិការភាព**

**នៃការធានារ៉ាប់រងអាយុជីវិត" (JR / T0083-2013) ដែលចេញដោយគណៈកម្មាធិការគ្រប់គ្រងធានារ៉ាប់រងចិន [ឆ្នាំ 2014] លេខ 6) ប្រសិនបើពិការភាពត្រូវបានចុះបញ្ជី វាត្រូវបានគេចាត់ទុកថាត្រូវបានបង់ប្រាក់សម្រាប់ការធានារ៉ាប់រងពិការភាពដោយគ្រោះថ្នាក់ចៃដន្យរួចរាល់ហើយ ។**

ចំនួនទឹកប្រាក់ទូទាត់លើការធានារ៉ាប់រងសម្រាប់ពិការភាពដោយគ្រោះថ្នាក់ចៃដន្យ ការស្លាប់ដោយគ្រោះថ្នាក់ចៃដន្យរឺដោយជម្ងឺ និងទឹកប្រាក់ទូទាត់បូកសរុបទាំងអស់ គឺមានកំណត់។ នៅពេលដែលចំនួនទឹកប្រាក់បង់ទូទាត់សរុបកើនដល់ចំនួនទឹកប្រាក់ធានារ៉ាប់រង ការធានារ៉ាប់រងផ្នែកនេះនឹងត្រូវបានបញ្ចប់។

**សម្គាល់: បទដ្ឋានស្តង់ដារនិងកូដវាយតម្លៃភាពពិការនៃការធានារ៉ាប់រងអាយុជីវិត(JR / T0083-2013) ដែលចេញដោយគណៈកម្មាធិការធានារ៉ាប់រងចិន [ឆ្នាំ 2014] លេខ 6អាចចុះឈ្មោះចូលមើលនៅលើគេហទំព័ររបស់សមាគមធានារ៉ាប់រងចិន។**

3. **ការទទួលខុសត្រូវចំពោះការធានារ៉ាប់រងលើការព្យាបាលថែទាំផ្នែកវេជ្ជសាស្រ្ត៖**

ក្នុងករណីអ្នកទទួលសេវាធានារ៉ាប់រងជួបគ្រោះថ្នាក់ហើយត្រូវបានព្យាបាល**ក្នុងរយៈពេល 180 ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុ** ក្រុមហ៊ុនធានារ៉ាប់រងត្រូវទូទាត់អោយ 100% លើថ្លៃធានារ៉ាប់រង សម្រាប់ការចំណាយជាក់ស្តែងដោយសមហេតុផលនិងចាំបាច់លើផ្នែកវេជ្ជសាស្រ្ត ហើយការទូទាត់ត្រូវបានកំណត់ត្រឹម 20,000 យ័ន ។

មិនថាអ្នកទទួលសេវាធានារ៉ាប់រងមានគ្រោះថ្នាក់មួយលើករឺច្រើនលើក ក្រុមហ៊ុនត្រូវបង់ប្រាក់ធានារ៉ាប់រងដោយយោងទៅតាមបទប្បញ្ញត្តិខាងលើ"ប្រាក់ធានារ៉ាប់រងវេជ្ជសាស្រ្ត" ប៉ុន្តែចំនួនទឹកប្រាក់ទូទាត់មិនលើសពីចំនួនទឹកប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់របស់អ្នកទទួលសេវាធានារ៉ាប់រង ហើយនៅពេលចំនួនទឹកប្រាក់ទូទាត់សរុបកើនឡើងដល់ចំនួនទឹកប្រាក់កំណត់សម្រាប់ការធានារ៉ាប់រងផ្នែកវេជ្ជសាស្រ្ត ការផ្តល់ជូននូវទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវបានបញ្ចប់។

**រួមមាន៖** ការរងរបួសដោយចៃដន្យដែលបណ្តាលមកពីការបុកទង្គិច រលាក របួសសន្លាកជើង មុតដៃពេលហាន់បន្លែ សត្វឆ្មារឺឆ្កែខាំរឺខ្វាច។ ល។

**រូបមន្តសំណង៖** ប្រាក់ចំណាយសមហេតុផលសរុប × 100% = ចំនួនទឹកប្រាក់ដែលអាចទទួលមកវិញ (ប្រាក់ចំណាយសមហេតុផលសរុបមិនរាប់បញ្ចូលចំណាយផ្ទាល់ខ្លួន និងការចំណាយហិរញ្ញវត្ថុខ្លួនឯងដោយផ្នែកដែលត្រូវបានកំណត់ដោយសេវាធានារ៉ាប់រងសុខភាពមូលដ្ឋាននៅក្នុងតំបន់) ។

4. **ការធានារ៉ាប់រងលើផ្នែកវេជ្ជសាស្រ្តក្នុងការទទួលព្យាបាលទូទៅនិងសង្គ្រោះបន្ទាន់:**

ក្នុងកំឡុងពេលធានារ៉ាប់រងនៅមានសុពលភាព ក្នុងករណីអ្នកទទួលសេវាធានារ៉ាប់រងត្រូវធ្វើការចំណាយដោយសមហេតុផលនិងចាំបាច់លើការថែទាំវេជ្ជសាស្ត្រព្យាបាលជម្ងឺទាំងផ្នែកទូទៅនិងផ្នែកសង្គ្រោះបន្ទាន់ **ទឹកប្រាក់ព្យាបាលប្រចាំថ្ងៃកំណត់ត្រឹម60 0យ័ន (ប្រសិនបើការចំណាយខាងវេជ្ជសាស្ត្រ**

**ក្នុងមួយថ្ងៃលើសពីដែនកំណត់ប្រចាំថ្ងៃនោះអាចគណនាបានត្រឹមតែ600យ៉េនប៉ុណ្ណោះ ហើយបើថ្លៃព្យាបាលប្រចាំថ្ងៃមិនលើសពីចំនួនកំណត់600យ៉េន នោះនឹងធ្វើការគណនាតាមចំនួនជាក់ស្តែង)។ ផ្នែកលើមូលដ្ឋាននៃចំនួនកំណត់ប្រចាំថ្ងៃ ផ្នែកនៃចំនួនសរុបដែលលើសពី 650 យ៉េន ត្រូវបង់ដោយគិតត្រឹម 85%** ហើយចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបកំណត់ត្រឹម 20,000 យ៉េន។ នៅពេលដែលចំនួនទឹកប្រាក់ទូទាត់កើនឡើងដល់ចំនួនធានារ៉ាប់រងដែលបានកំណត់ ការធានារ៉ាប់រងលើផ្នែកនេះនឹងត្រូវបានបញ្ចប់។

**ការចំណាយលើការព្យាបាលផ្នែកទូទៅនិងបន្ទាន់រួមមាន៖** ចំណាយនានាទាក់ទងនឹងការព្យាបាលជំងឺទូទៅនិងបន្ទាន់ ការវះកាត់ព្យាបាលទូទៅ ការតាមដានក្នុងផ្នែកសង្គ្រោះបន្ទាន់ ការជួយសង្គ្រោះបន្ទាន់។ លិខិតបញ្ជាក់ពីការចំណាយនានាក្នុងកំឡុងពេលសំរាក់ផ្តាច់ខ្លួនដោយករណីឆ្លងជម្ងឺត្រូវចេញដោយមន្ទីរពេទ្យសាធារណៈ ឬមន្ទីរបង្ការសុខភាព និងរោគរាតត្បាតសាធារណៈ។ ការចំណាយព្យាបាលក្នុងផ្នែកទូទៅដែលកើតឡើងមុននិងក្រោយមន្ទីរពេទ្យដោយសារជំងឺនេះ ត្រូវបានរាប់បញ្ចូលក្នុងលក្ខខណ្ឌធានារ៉ាប់រងលើផ្នែកវេជ្ជសាស្ត្រព្យាបាលទូទៅនិងបន្ទាន់។

**រួមមាន៖** ករណីព្យាបាលនៅផ្នែកទូទៅឬផ្នែកសង្គ្រោះបន្ទាន់ដោយសារគ្រុនក្តៅ ឈឺពោះភ្លាមៗ ដួលសន្លប់ ការរលាកនៅកន្លែងណាមួយនៅក្នុងរាងកាយ ។ ល។

**រូបមន្តសំណង៖ (ប្រាក់ចំណាយប្រចាំថ្ងៃដែលស្ថិតក្រោមប្រាក់កំណត់600យ៉េនបូកនឹង -650 យ៉េន)** × **85% = ប្រាក់ចំណាយដែលអាចទទួលបានមកវិញ** (ប្រាក់ចំណាយសមហេតុផលសរុបមិនរាប់បញ្ចូលចំណាយផ្ទាល់ខ្លួន និងការចំណាយហិរញ្ញវត្ថុខ្លួនឯងដោយផ្នែកដែលត្រូវបានកំណត់ដោយសេវាធានារ៉ាប់រងសុខភាពមូលដ្ឋាននៅក្នុងតំបន់) ។

**និយមន័យ៖**

**ដែនកំណត់ប្រចាំថ្ងៃ៖ ចំនួនកំណត់ថ្លៃអតិបរមាសម្រាប់ការព្យាបាលប្រចាំថ្ងៃ។**

**អាចដកបាន៖ ប្រភេទធានារ៉ាប់រងនេះកំណត់ 650 យ៉េនជាប្រាក់ដែលអាចដកបាន (650យ៉េននឹងត្រូវកាត់ម្តងក្នុងកំឡុងពេលធានារ៉ាប់រង) ហើយផ្នែកដែលនៅខាងក្រោមប្រាក់ដកនឹងមិនត្រូវបានទូទាត់សងទេ។**

5. **ការទទួលខុសត្រូវចំពោះការធានារ៉ាប់រងថែទាំលើផ្នែកវេជ្ជសាស្ត្រកំឡុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ៖**

ក្នុងករណីអ្នកទទួលសេវាធានារ៉ាប់រងទទួលរងនូវគ្រោះថ្នាក់ចៃដន្យឬជំងឺ ហើយត្រូវតែសម្រាកព្យាបាលនៅមន្ទីរពេទ្យបន្ទាប់ពីត្រូវបានធ្វើរោគវិនិច្ឆ័យ នោះក្រុមហ៊ុននឹងបង់ថ្លៃថែទាំដោយសមរម្យនិងចាំបាច់ទៅតាមចំណាយជាក់ស្តែង **(កំណត់ 200 យ៉េន / ថ្ងៃរហូតដល់ត្រឹម 60 ថ្ងៃ)** ។ថ្លៃកំណត់គ្រាជម្ងឺ ថ្លៃកំដៅ ថ្លៃម៉ាស៊ីនត្រជាក់ ថ្លៃគ្រែ ថ្លៃសេវាអធិការកិច្ចថ្លៃឈ្នួលត្រួតពិនិត្យ ថ្លៃពិនិត្យនិងព្យាបាលពិសេស ថ្លៃវះកាត់ ថ្លៃថ្នាំ ថ្លៃព្យាបាល ថ្លៃពិសោធន៍ ថ្លៃបាញ់កាំរស្មី និងថ្លៃចំណាយសមស្របផ្សេងៗ

ត្រូវគិតតាមសមាមាត្រ100%បង់ជូនអ្នកជម្ងឺស្របតាម "ការធានារ៉ាប់រងលើការថែទាំវេជ្ជសាស្ត្រកំឡុងសម្រាកក្នុងមន្ទីរពេទ្យ"។
ក្នុងកំឡុងពេលធានារ៉ាប់រងមិនថាអ្នកជម្ងឺចូលមន្ទីរពេទ្យមួយលើកវឺច្រើនលើកទេ ក្រុមហ៊ុននឹងបង់ថ្លៃធានារ៉ាប់រងយោងតាមវិធានបទប្បញ្ញត្តិដែលបានចែង។ រាល់ពេលដែលប្រាក់ធានារ៉ាប់រងសម្រាប់អ្នកជំងឺកើនដល់ 400,000 យ័ន ការធានារ៉ាប់រងក្នុងផ្នែកនេះនឹងត្រូវបានបញ្ចប់។
**រួមមាន៖** ប្រសិនបើមានរងរបួសឬមានជម្ងឺត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យបន្ទាប់ពីបានធ្វើរោគវិនិច្ឆ័យដោយមន្ទីរពេទ្យ អ្នកជម្ងឺអាចដាក់ពាក្យសុំសំណងធានារ៉ាប់រង បន្ទាប់ពីស្នើសុំបង់ប្រាក់មន្ទីរពេទ្យជាមុនឬបង់ដោយខ្លួនអ្នក។
**រូបមន្តសំណង៖** ប្រាក់ចំណាយសមហេតុផលក្នុងមន្ទីរពេទ្យ × 100% = ប្រាក់ចំណាយដែលអាចទទួលមកវិញ (ប្រាក់ចំណាយសមហេតុផលសរុបមិនរាប់បញ្ចូលចំណាយផ្ទាល់ខ្លួន និងការចំណាយហិរញ្ញវត្ថុខ្លួនឯងដោយផ្នែកដែលត្រូវបានកំណត់ដោយសេវាធានារ៉ាប់រងសុខភាពមូលដ្ឋាននៅក្នុងតំបន់) ។

**សម្គាល់:**

**1). ចំពោះការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រទាំងអស់ខាងលើ គឺសម្តៅលើតែមន្ទីរពេទ្យរដ្ឋទាំងឡាយណាដែលស្ថិតនៅសាធារណរដ្ឋប្រជាមានិតចិនដីគោកតែប៉ុណ្ណោះ។ ប្រសិនបើអ្នកទទួលសេវាធានារ៉ាប់រងទទួលសេវាព្យាបាល និងស្នាក់នៅបន្ទប់ព្យាបាលសម្រាប់ជនបរទេស បន្ទប់VIP បន្ទប់ឯកជន បន្ទប់កំរិតA បន្ទប់ទោល បន្ទប់ពិគ្រោះព្យាបាលកំរិតពិសេសជាដើម ក្រុមហ៊ុននឹងមិនរ៉ាប់រងចំពោះការចំនាយនោះទេ។**

**2). ចំពោះការធានារ៉ាប់រងនៃចំណាយផ្នែកវេជ្ជសាស្ត្រទាំងអស់ខាងលើ ត្រូវបានកំណត់ចំពោះតែការចំណាយលើគម្រោងធានារ៉ាប់រងសុខភាពកំរិតមូលដ្ឋានរបស់សហគមន៍ក្នុងតំបន់តែប៉ុណ្ណោះ។ ចំពោះគម្រោងសេវាដែលតម្រូវអោយបង់ថ្លៃដោយខ្លួនឯងទាំងអស់ឬដោយផ្នែក ក្រុមហ៊ុននឹងមិនផ្តល់សំណងទេ។**

**3). ចំពោះអ្នកដែលទើបតែទទួលសេវាធានារ៉ាប់រងជាលើកដំបូង វឺអ្នកមិនបានបន្តបង់ថ្លៃសេវាធានារ៉ាប់រងជាអចិន្ត្រៃយ៍ ក្នុងរយៈពេល30ថ្ងៃ គិតចាប់ពីថ្ងៃជាវសេវាធានារ៉ាប់រង គឺត្រូវចាត់ទុកថាស្ថិតនៅក្នុង "កំឡុងពេលរង់ចាំ" (រយៈពេលសង្កេត) ។ ប្រសិនបើមានការពិគ្រោះព្យាបាល ឬសំរាកព្យាបាលនៅមន្ទីរពេទ្យកើតឡើងក្នុង "កំឡុងពេលរង់ចាំ" ក្រុមហ៊ុននឹងមិនទទួលខុសត្រូវឡើយ។ សម្រាប់អ្នកទទួលសេវាធានារ៉ាប់រងជាអចិន្ត្រៃយ៍គឺមិនមាន " កំឡុងពេលរង់ចាំ" (រយៈពេលសង្កេត) នោះទេ។**

**4). ចំពោះការចំណាយខាងវេជ្ជសាស្ត្រទាំងអស់ខាងលើ ប្រសិនបើមានភាគីទីបីបង់ថ្លៃចំណាយមួយផ្នែកឬទាំងស្រុង ក្រុមហ៊ុននឹងធានារ៉ាប់រងតែចំណាយដែលនៅសេសសល់ដែលមានកំណត់នៅក្នុងកញ្ចប់គម្រោងធានារ៉ាប់រងសុខភាពកំរិតមូលដ្ឋានរបស់សហគមន៍ក្នុងតំបន់តែប៉ុណ្ណោះ។ ដែនកំណត់**

នៃថ្លៃគ្រែ ថ្លៃថែទាំ ថ្លៃសេវាបន្ទប់ពិគ្រោះឬបន្ទប់សង្គ្រោះបន្ទាន់ និងប្រាក់ឧបត្ថម្ភពេលមានអាសន្ន ដែលពាក់ព័ន្ធនឹងការធានារ៉ាប់រង ក៏ត្រូវបានកំណត់ផងដែរ។ ប្រសិនបើភាគីទីបីមានចំណែកសមាមាត្រនៃសំណង ក្រុមហ៊ុននឹងធានារ៉ាប់រងតែថ្លៃសេវាដែលមានក្នុងការកំណត់ ដែលនៅសេសសល់បន្ទាប់ពីភាគីទីបីបានសងរួចប៉ុណ្ណោះ។ ប្រសិនបើមិនមានសមាមាត្រសំណងទេ ថ្លៃធានារ៉ាប់រងគឺកំណត់ដោយយកតម្លៃស្តង់ដារធានារ៉ាប់រងដកថ្លៃកំណត់រ៉ាប់រងវេជ្ជសាស្ត្ររបស់ទីតាំងមូលដ្ឋាន រួចក្រុមហ៊ុននឹងបង់ថ្លៃដែលនៅសេលសល់ប៉ណ្ណោះ។ ហើយចំនួនទឹកប្រាក់ធានារ៉ាប់រងគឺមានកំណត់។

5). ប្រសិនបើអ្នកទទួលសេវាធានារ៉ាប់រងមានជំងឺធ្ងន់ធ្ងរ ឬជំងឺរ៉ាំរ៉ៃមុនពេលជាវសេវាធានារ៉ាប់រង ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះការបង់ថ្លៃធានារ៉ាប់រងឡើយ។

ករណីរួចផុតពីការទទួលខុសត្រូវ

I. ចំពោះសេវាធានារ៉ាប់រងផ្នែកមរណភាព និងពិការភាពដោយចៃដន្យ

ប្រសិនបើអ្នកទទួលសេវាធានារ៉ាប់រងស្លាប់ឬពិការដោយករណីណាមួយខាងក្រោម ក្រុមហ៊ុននឹងមិនទទួលខុសត្រូវធានារ៉ាប់រងទេះ

(1) អតិថិជនសេវាធានារ៉ាប់រង ឬអ្នករងចាំទទួលផលបង្គរបួស ឬសម្លាប់អ្នកដែលទទួលសេវាធានារ៉ាប់រងដោយចេតនា

(2) អ្នកទទួលសេវាធានារ៉ាប់រងធ្វើទារុណកម្មខ្លួនឯងដោយចេតនា ធ្វើអត្តឃាត ប្រព្រឹត្ត ឬប្រឆាំងដោយចេតនានឹងវិធានការជាកាតព្វកិច្ចអនុវត្តតាមរបស់ច្បាប់ព្រហ្មទណ្ឌ។

(3) អ្នកទទួលសេវាធានារ៉ាប់រងស្ថិតក្នុងភាពស្រវឹង ឬស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង, ប្រើប្រាស់គ្រឿងញៀន ឬជាតិពុលដោយចេតនា។

(4) អ្នកធានារ៉ាប់រងបើកបរយានយន្តបន្ទាប់ពីសេពគ្រឿងស្រវឹង បើកបរយានយន្តដោយគ្មានបណ្ណបើកបរត្រឹមត្រូវ និងបើកបរយានយន្តដោយប្រើប័ណ្ណបើកបរគ្មានសុពលភាព។

(5) ករណីទំនាស់ ជម្លោះយោធា កុបកម្ម ឬការបះបោរប្រដាប់អាវុធផ្សេងៗ។

(6) ការផ្ទុះនុយក្លេអ៊ែរ វិទ្យុសកម្មនុយក្លេអ៊ែរ ឬការបំពុលបរិយាកាសដោយនុយក្លេអ៊ែរ

(7) ផលអវិជ្ជមានផ្សេងៗដែលបង្កមកពីការមានផ្ទៃពោះ ការរលូតកូន ការសម្រាលកូន (រាប់បញ្ចូលផ្នែកវះកាត់) ការពន្យាកំណើតឬក្រៀវដោយការវះកាត់, ការព្យាបាលភាពគ្មានកូន ការមានផ្ទៃពោះសិប្បនិម្មិត។

(8) ផលអវិជ្ជមានផ្សេងៗដែលបង្កមកពីការវះកាត់កែសម្ផស្ស ឬឧបវហេតុផ្នែកវេជ្ជសាស្ត្រផ្សេងៗ។

(9) អ្នកទទួលសេវាធានារ៉ាប់រងមិនគោរពតាមវេជ្ជបញ្ជា ប្រើប្រាស់ថ្នាំផ្តេសផ្តាស។ ប៉ុន្តែការប្រើប្រាស់ដោយសមស្របតាមសៀវភៅណែនាំនូវថ្នាំដែលមិនតម្រូវអោយមានវេជ្ជបញ្ជា គឺមិនត្រូវបានកំណត់ចំពោះបញ្ហានេះឡើយ។

(10) អ្នកទទួលសេវាធានារ៉ាប់រងមានកើតជំងឺអេដស៍ (AIDS) ឬឆ្លងមេរោគអេដស៍ (HIVវិជ្ជមាន) ។

(11) អ្នកទទួលសេវាធានារ៉ាប់រងបានចូលរួមនៅក្នុងកីឡាដែលមានហានិភ័យខ្ពស់ដូចជាកីឡាជ្រមុជទឹក លោតឆ័ត្រយោង ឡើងថ្មាំងថ្ម ដំណើរផ្សងព្រេង ចំបាប់ ការប្រកួតប្រជែងសិល្បៈក្បាច់គុន ប្រណាំងឡាន ។ល។

(12) អ្នកទទួលសេវាធានារ៉ាប់រងស្លាប់ ឬពិការនៅខាងក្រៅនៃប្រទេសចិនដីគោក។

(13) ផ្តល់ព័ត៌មានមិនពិត អ្នកជំនាញឬគ្រូបរទេសក្លែងបន្លំជានិស្សិតដាក់ពាក្យសុំសេវាធានារ៉ាប់រង ។

(14) គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលបំពេញការងារក្នុងពេលសិក្សានៅបរទេស (ការងារដែលផ្តល់ដោយខាងសាលារៀន)។

នៅក្នុងស្ថានភាពមួយក្នុងចំណោមស្ថានភាពខាងលើ ប្រសិនបើអ្នកទទួលសេវាធានារ៉ាប់រងបានស្លាប់ ក្រុមហ៊ុនមិនមានទំនួលខុសត្រូវអ្វីឡើយ ។

II . ផ្នែកវេជ្ជសាស្ត្រ (ករណីរងគ្រោះដោយយថាហេតុ សេវាពិគ្រោះព្យាបាលទូទៅ សេវាសង្គ្រោះបន្ទាន់ សេវាសម្រាកព្យាបាល )

ប្រសិនបើអ្នកទទួលសេវាធានារ៉ាប់រងស្លាប់ឬពិការដោយករណីណាមួយខាងក្រោម ក្រុមហ៊ុននឹងមិនទទួលខុសត្រូវធានារ៉ាប់រងទេះ

(1) អ្នកជាវសេវាធានារ៉ាប់រង ឬអ្នកចាំទទួលផលបង្ករបួស ឬសម្លាប់អ្នកទទួលសេវាធានារ៉ាប់រងដោយចេតនា

(2) ការធ្វើទារុណកម្មខ្លួនឯងដោយចេតនា ប្រព្រឹត្តបទឧក្រិដ្ឋ រឺប្រឆាំងនឹងវិធានការអនុវត្តតាមច្បាប់ដែលជាកាតព្វកិច្ចព្រហ្មទណ្ឌ។

(3) អ្នកទទួលសេវាធានារ៉ាប់រងស្ថិតក្នុងភាពស្រវឹង ឬស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ប្រើប្រាស់គ្រឿងញៀន ឬជាតិពុលដោយចេតនា។

(4) អ្នកធានារ៉ាប់រងបើកបរយានយន្តបន្ទាប់ពីសេពគ្រឿងស្រវឹង បើកបរយានយន្តដោយគ្មានបណ្ណបើកបរត្រឹមត្រូវ និងបើកបរយានយន្តដោយប្រើប័ណ្ណបើកបរគ្មានសុពលភាព។

(5) ករណីទំនាស់ ជម្លោះយោធា កុបកម្ម ឬការបះបោរប្រដាប់អាវុធផ្សេងៗ។

(6) ការផ្ទុះនុយក្លេអ៊ែរ វិទ្យុសកម្មនុយក្លេអ៊ែរ ឬការបំពុលបរិយាកាសដោយនុយក្លេអ៊ែរ

(7) អ្នកទទួលសេវាធានារ៉ាប់រងមានជំងឺពីកំណើត ជំងឺតំណពូជ ឬប្រវត្តិជំងឺកន្លងមក (មានរោគសញ្ញា ឬជំងឺស្រាប់មុនពេលជាវសេវាកម្ម មានជំងឺចន្លោះពេល ”កំឡុងពេលរង់ចាំ”)

(8) អ្នកទទួលសេវាកម្មមានជំងឺអេដស៍ ឬឆ្លងមេរោគអេដស៍ ឬជំងឺកាមរោគ។

(9) ផលអវិជ្ជមានផ្សេងៗដែលបង្កមកពីការមានផ្ទៃពោះ ការរលូតកូន ការសម្រាលកូន ការព្យាបាលភាពគ្មានកូន ការមានផ្ទៃពោះសិប្បនិម្មិត ការពិនិត្យសុខភាពមុន និងក្រោយពេលសម្រាលកូន នឹងបច្ចេសទេសគ្រប់គ្រងកំណើត។

(10) ផលអវិជ្ជមានផ្សេងៗដែលបង្កមកពីការវះកាត់កែសម្ផស ឬឧបវ័ផ្នែកវេជ្ជសាស្ត្រហេតុផ្សេងៗ។

(11) ការចំណាយសេវាទន្តពេទ្យដោយសារតែការថែទាំធ្មេញ (ដូចជាការសំអាតធ្មេញ, ប្តូរធ្មេញ ប៉ះធ្មេញ ដាក់ធ្មេញ និងការចំណាយក្នុងការជួសជុលមាត់ធ្មេញ ការថែទាំសុខភាពមាត់ និងការកែសម្រស់ជាដើម)។ ការដាក់ធ្មេញដែលបណ្តាលមកពីដង្កូវស៊ីធ្មេញ ជំងឺបណ្តូលធ្មេញ ធ្មេញប្រេះស្រាំ ការព្យាបាលសរសៃប្រសាទធ្មេញ ដកធ្មេញ និងជំងឺជាលិការជុំវិញធ្មេញ (ជំងឺអញ្ចាញធ្មេញជាដើម) សុទ្ធតែស្ថិតក្នុងទំនួលខុសត្រូវរ៉ាប់រងរបស់ក្រុមហ៊ុន។

(12) ការចំណាយលើការព្យាបាលដោយមានការពាត់ពែន កែប្រែ តម្រង់រូបរាង ការស្តារនីតិសម្បទាជាដើម។

(13) ការចំណាយលើការពិនិត្យតាមដានសុខភាពជាប្រចាំ ការស្ទង់មតិជំងឺ សេវាកម្មបង្កាការពារសុខភាពផ្សេងៗ សេវាថែរក្សាសុខភាព សេវាធ្វើរោគវិនិច្ឆ័យ និងការព្យាបាលពិសេសដូចជា ៖ ការចាក់វ៉ាក់សាំងវ៉ាក់សាំងផ្សេងៗ ការព្យាបាលដោយចលនាម៉ាស្សាជើង សេវាម៉ាស្សាខ្លួននិងគម្រោងផ្សេងទៀត។

(14) ការមិនគោរពតាមវេជ្ជបញ្ជា ប្រើប្រាស់ថ្នាំផ្តេសផ្តាសជាដើម។

(15) ការចំណាយខាងវេជ្ជសាស្ត្រនៅខាងក្រៅប្រទេសចិនដីគោក និងចំណាយនៅមន្ទីរពេទ្យឯកជន (រួមទាំងប្រទេសចិនដីគោក) និងការចំណាយទៅលើឱសថស្ថាន និងក្រុមហ៊ុនឧបករណ៍វេជ្ជសាស្ត្រ។

(16) គ្រោះថ្នាក់កើតឡើងនៅខាងក្រៅប្រទេសចិនដីគោក និងថ្លៃតាមដានព្យាបាលបន្តបន្ទាប់ពីគ្រោះថ្នាក់។

(17) ការចំណាយថ្លៃសេវាទូរស័ព្ទ មធ្យោបាយធ្វើដំណើរ។ ល។

(18) អត្តពលិកចូលរួមសកម្មភាពកីឡាដែលមានហានិភ័យខ្ពស់ (ដូចជាកីឡាលោត មុជទឹក លោតឆ័ត្រយោង ជិះស្គី លោតលើបឹង បោកចំបាប់ យូដូ តេក្វាន់ដូ ក្បាច់គុនការ៉ាតេ។ល។) ។

(19) ផ្តល់ព័ត៌មានមិនពិត អ្នកជំនាញឬគ្រូបរទេសក្លែងបន្លំជានិស្សិតដាក់ពាក្យសុំសេវាធានារ៉ាប់រង។

(20) ការចំណាយដែលកើតឡើងដោយសេវាព្យាបាលបែបពិសោធន៍សាកល្បង ហើយក្នុងគោលបំណងពិសោធន៍វេជ្ជសាស្ត្រ។

(21) ដោយផ្អែកលើស្តង់ដាររបស់មន្ទីរពេទ្យក្នុងការវិនិច្ឆ័យទទួលអ្នកជំងឺចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ អ្នកទទួលសេវារ៉ាប់រងមិនបានបំពេញលក្ខខណ្ឌចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យទេ ប៉ុន្តែអ្នកទទួលសេវារ៉ាប់រងទាមទារចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

(22) ការចំណាយទាក់ទងនឹងការពិគ្រោះយោបល់ដោយមិនបានទំនាក់ទំនងទូរស័ព្ទលេខ 400 ជាមុន ឬការស្នើសុំមិនទាន់មានការឆ្លើយតប។

(23) គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលបំពេញការងារក្នុងពេលសិក្សានៅបរទេស (ការងារដែលផ្តល់ដោយខាងសាលារៀន)។

តម្លៃធានារ៉ាប់រង

<table>
<tr><td rowspan="2">ការធានារ៉ាប់រង</td><td rowspan="2">តម្លៃធានា (យ័ន) RMB</td><td colspan="2">8ឆ្នាំ—69ឆ្នាំ</td></tr>
<tr><td>តម្លៃធានារ៉ាប់រង (យ័ន/នាក់·កន្លះឆ្នាំ )</td><td>តម្លៃធានារ៉ាប់រង (យ័ន/នាក់·ឆ្នាំ)</td></tr>
<tr><td>មរណភាព + ពិការភាពដោយចៃដន្យ</td><td>100000</td><td rowspan="4">400</td><td rowspan="4">800</td></tr>
<tr><td>ឧបរហេតុផ្នែកវេជ្ជសាស្ត្រ</td><td>20000</td></tr>
<tr><td>សេវាព្យាបាលផ្នែកពិគ្រោះជំងឺនិងសង្គ្រោះបន្ទាន់ (តម្លៃកំណត់សេវាប្រចាំថ្ងៃគឺ 600 យ័ន 650យ័នឬច្រើនជាងនេះត្រូវបង់ 85% )</td><td>20000</td></tr>
<tr><td>ការស្នាក់នៅមន្ទីរពេទ្យ</td><td>400000</td></tr>
</table>

សម្គាល់: ចំពោះបញ្ហាដែលមិនទាន់បានបញ្ចប់《ក្រុមហ៊ុនភីងអាន ភ្ជាប់ការការពារធានារ៉ាប់រងលើពិការភាពដោយចៃដន្យ (ឆ្នាំ 2013) (ផ្នែកD) 》 《ក្រុមហ៊ុនភីងអាន ការធានារ៉ាប់រងអាយុជីវិតជាក្រុមរយៈពេលមួយឆ្នាំ》 《ក្រុមហ៊ុនភីងអាន ភ្ជាប់ការធានារ៉ាប់រងព្យាបាលផ្នែករបួសដោយចៃដន្យជាក្រុម》 《ក្រុមហ៊ុនភីងអាន ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រខាងពិគ្រោះជំងឺនិងសង្គ្រោះបន្ទាន់ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ》《ក្រុមហ៊ុនភីងអាន ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្ររបស់ក្រុមអ្នកជំងឺស្នាក់នៅមន្ទីរពេទ្យ》 《ក្រុមហ៊ុនភីងអាន ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្ររបស់ក្រុមផ្តល់ជំនួយ (ផ្នែកA)》 និងលក្ខខណ្ឌផ្សេងទៀត។

ករណីខ្លឹមសារខាងលើមានការជំទាស់ គឺត្រូវយកឯកសារភាសាចិនជាគោល។

## សូមទូរស័ព្ទសាកសួរ4008105119 មុននឹងទទួលសេវាពិគ្រោះសេវាសុខភាពផ្សេងៗ

**អតិថិជនជាទីគោរព:**

**ប្រសិនបើអ្នកចង់ដឹងអំពីសេវាកម្មទាមទារសំណងធានារ៉ាប់រងដ៏ទូលំទូលាយរបស់ ក្រុមហ៊ុនធានារ៉ាប់រងភីងអាន អិលធីឌីសូមអានដោយយកចិត្តទុកដាក់ពីព័ត៌មានដូចខាងក្រោម ។**

I. នីតិវិធីការទាមទារ:

បន្ទាប់ពីការកើតឡើងនៃគ្រោះថ្នាក់ធានារ៉ាប់រង នីតិវិធីស្តង់ដារសម្រាប់បណ្តឹងទាមទារសំណង៖

ទូរស័ព្ទសម្រាប់ពិគ្រោះនិងរាយការណ៍: 4008105119

ប្រសិនមានជំងឺឬគ្រោះថ្នាក់ត្រូវការជួបគ្រូពេទ្យ ត្រូវហៅទូរស័ព្ទទៅលេខ 4008105119 ដោយផ្ទាល់ហើយគ្រូពេទ្យសង្គ្រោះនឹងផ្តល់ការពិគ្រោះយោបល់សុខភាព ការណែនាំវេជ្ជសាស្ត្រនិងការណែនាំសម្រាប់ការទាមទារសំណង។ ប្រសិនបើវេជ្ជបណ្ឌិតបានបញ្ជាក់ពីតម្រូវការក្នុងការចូលមន្ទីរពេទ្យបន្ថែមទៀតបន្ទាប់ពីពិគ្រោះនិងព្យាបាល អ្នកជំងឺគាត់អាចដាក់ពាក្យសុំទៅក្រុមហ៊ុនជួយសង្គ្រោះសម្រាប់ការបង់ប្រាក់ជាមុននៅមន្ទីរពេទ្យ ហើយក្រុមហ៊ុនសង្គ្រោះនឹងសំរេចថាតើត្រូវចាប់ផ្តើមនីតិវិធីបង់ប្រាក់ជាមុននៅមន្ទីរពេទ្យឬអត់បន្ទាប់ពីទំនាក់ទំនងជាមួយមន្ទីរពេទ្យ។ **ក្រុមហ៊ុនជួយសង្គ្រោះមិនទទួលខុសត្រូវចំពោះការបង់ប្រាក់ជាមុននៃថ្លៃព្យាបាលនៅមន្ទីរពេទ្យ សម្រាប់អ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរ**

**ពេទ្យដោយផ្ទាល់ដោយមិនបានឆ្លងកាត់ការពិគ្រោះនិងកត់ត្រាដោយវេជ្ជបណ្ឌិតនៃក្រុមហ៊ុនជួយសង្គ្រោះនិងដោយគ្មានការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលនៅខាងក្រៅ។ សម្រាប់បុគ្គលដែលមិនអនុវត្តតាមនីតិវិធីខាងលើ បុគ្គលដែលចំណាយលើថ្លៃព្យាបាលដោយខ្លួនឯងនឹងមិនត្រូវបានផ្តល់សំណងឡើយ។**

**II. ឯកសារដែលត្រូវត្រៀមសំរាប់ការទាមទារសំណង៖**

1) . មរណភាពឬពិការភាពដោយចៃដន្យ

A. ច្បាប់ថតចំលងលិខិតឆ្លងដែននិងទំព័រទិដ្ឋាការរបស់អ្នកត្រូវបានធានារ៉ាប់រង

B. ផ្តល់វិញ្ញាបនប័ត្រវាយតម្លៃភាពពិការរបស់អ្នកត្រូវបានធានារ៉ាប់រង (របាយការណ៍វាយតម្លៃត្រូវចេញដោយទីភ្នាក់ងារវាយតម្លៃដែលបានកំណត់)

C. លិខិតបញ្ជាក់មរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង

D. ច្បាប់ចម្លងនៃលិខិតបញ្ជាក់ទំនាក់ទំនងរវាងអ្នកធានារ៉ាប់រងនិងអ្នកទទួលផលទាំងអស់និងលិខិតបញ្ជាក់អត្តសញ្ញាណរបស់អ្នកទទួលផល

E. ប្រសិនបើមានឧបទ្ទវហេតុណាមួយត្រូវផ្តល់ឯកសារបញ្ជាក់ពីគ្រោះថ្នាក់និងឯកសារពីមន្ទីរពាក់ព័ន្ធផ្សេងៗ (ដូចជា ករណីគ្រោះថ្នាក់ចរាចរណ៍ត្រូវផ្តល់ឯកសារបញ្ជាក់ពីគ្រោះថ្នាក់ចរាចរណ៍ដែលបញ្ជាក់ពីនាយកដ្ឋានចរាចរណ៍។ ការដួលពីកំពស់ខ្ពស់ ការលង់ទឹក ។ល។ ត្រូវផ្តល់ឯកសាដែលបញ្ជាក់ពីគ្រោះថ្នាក់ឬធ្វើអត្តឃាតដែលចេញពីសន្តិសុខសាធារណៈឬមន្ទីរពាក់ព័ន្ធហើយរបាយការណ៍បរិមាណជាតិអាល់កុលត្រូវផ្តល់ជូនសម្រាប់គ្រោះថ្នាក់ដែលបណ្តាលមកពីការផឹក) ។

2) . ការព្យាបាលសម្រាប់របួសដោយចៃដន្យ

A. ច្បាប់ថតចំលងលិខិតឆ្លងដែននិងទំព័រទិដ្ឋាការរបស់អ្នកត្រូវបានធានារ៉ាប់រង

B. ឯកសារបញ្ជាក់ពីគ្រោះថ្នាក់និងឯកសារបញ្ជាក់ផ្សេងៗ (ប្រសិនបើជាគ្រោះថ្នាក់ចរាចរណ៍វិញ្ញាបនបត្រនត្រូវមានការបញ្ជាក់ចំពោះគ្រោះថ្នាក់ចរាចរណ៍ដែលចេញដោយនាយកដ្ឋានចរាចរណ៍)

C. ច្បាប់ដើមបង្កាន់ដៃបង់ថ្លៃ

D. កំណត់ត្រាវេជ្ជសាស្ត្រដែលត្រូវគ្នានិងការពិគ្រោះម្តងៗ (កាលបរិច្ឆេទករណីពិគ្រោះត្រូវតែត្រូវគ្នានឹងកាលបរិច្ឆេទវិក្កយបត្រម្តងមួយៗ) ច្បាប់ថតចំលងពីព័ត៌មានលម្អិតនៃការចំណាយ ការថតត្រួតពិនិត្យ របាយការណ៍តេស្តមន្ទីរពិសោធន៍។

3) . ការព្យាបាលសង្គ្រោះបន្ទាន់

A. ច្បាប់ថតចំលងលិខិតឆ្លងដែននិងទំព័រទិដ្ឋាការរបស់អ្នកត្រូវបានធានារ៉ាប់រ

B. ច្បាប់ដើមបង្កាន់ដៃបង់ថ្លៃ

C. កំណត់ត្រាវេជ្ជសាស្ត្រដែលត្រូវគ្នានិងការពិគ្រោះម្តងៗ (កាលបរិច្ឆេទករណីពិគ្រោះត្រូវតែត្រូវគ្នានឹងកាលបរិច្ឆេទវិក្កយបត្រម្តងមួយៗ) ច្បាប់ថតចំលងពីព័ត៌មានលម្អិតនៃការចំណាយ ការថតត្រួតពិនិត្យ របាយការណ៍តេស្តមន្ទីរពិសោធន៍។

**ប្រសិនបើចំនួនទឹកប្រាក់សំណងលើសចំនួន 650 យ័ន ត្រូវផ្តល់ច្បាប់ចំលងនៃវិក្កយបត្រដើម កំណត់ត្រាវេជ្ជសាស្ត្រ ព័ត៌មានលម្អិតអំពីថ្លៃផ្សេងៗ របាយការណ៍តេស្តមន្ទីរពិសោធន៍។**

4) . ការស្នាក់នៅមន្ទីរពេទ្យ

A. ច្បាប់ថតចំលងលិខិតឆ្លងដែននិងទំព័រទិដ្ឋាការរបស់អ្នកត្រូវបានធានារ៉ាប់រង

B. ក្នុងករណីមានគ្រោះថ្នាក់ណាមួយវិញ្ញាបនប័ត្រគ្រោះថ្នាក់ត្រូវផ្តល់ជូន (ប្រសិនបើជាគ្រោះថ្នាក់ចរាចរណ៍លិខិតបញ្ជាក់ពីគ្រោះថ្នាក់ចរាចរណ៍ដែលចេញដោយនាយកដ្ឋានចរាចរណ៍។ ល។)

C. បង្កាន់ដៃដើមនៃការស្នាមន្ទីរពេទ្យ បង្កាន់ដៃដើមអំពីព័ត៌មានលម្អិតនៃតម្លៃផ្សេងៗ

D. ច្បាប់ថតចម្លងនៃសេចក្តីសង្ខេបពីការចាក់ចេញពីមន្ទីរពេទ្យឬកំណត់ត្រាវេជ្ជសាស្ត្រនៅមន្ទីរពេទ្យ

**ការណែនាំពិសេសសម្រាប់ 2) - 4) ខាងលើ:**

(1)នៅពេលដាក់ពាក្យបណ្តឹងទាមទារ ឯកសារសម្ភារៈ ត្រូវមានលេខគណនីធនាគាររបស់ចិនដីគោកដែលត្រូវបានការធានារ៉ាប់រង និងព័ត៌មានគណនីត្រឹមត្រូវរបស់គណនីរួមទាំងឈ្មោះគណនី លេខគណនី និងព័ត៌មានគណនីធនាគារ តាមរយៈសៀវភៅថតចំលងឬសំណុំបែបបទព័ត៌មានអតិថិជនរបស់ធនាគារ។ (ព័ត៌មានលម្អិតសូមទូរស័ព្ទទៅ 4008105119 ដើម្បីពិគ្រោះយោបល់)

(2)ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានគ្រោះថ្នាក់ម្តងត្រូវបានព្យាបាលនៅមន្ទីរពេទ្យពីរ (រួមទាំងពីរ)ការពិគ្រោះមន្ទីរពេទ្យរបស់មន្ទីរពេទ្យខាងលើចាំបាច់ត្រូវផ្តល់ឯកសារពាក់ព័ន្ធដូចជាលិខិតបញ្ជាក់ការធ្វើរោគវិនិច្ឆ័យនិងការថតចម្លងកំណត់ត្រាវេជ្ជសាស្ត្រសម្រាប់ការពិគ្រោះនីមួយៗ។

(3) មន្ទីរពេទ្យសម្រាប់ការព្យាបាលវេជ្ជសាស្ត្រត្រូវតែជាមន្ទីរពេទ្យរដ្ឋមួយនៅចិនដីគោកនៃសាធារណរដ្ឋប្រជាមានិតចិនហើយថ្លៃដើមនៃការដាក់ពាក្យសុំទាមទារសំណងគួរតែស្ថិតនៅក្នុងដែនកំណត់ដែលអាចទទួលយកបាននៃការធានារ៉ាប់រងសុខភាពសង្គមមូលដ្ឋាន។

5) . ពាក្យសុំថ្លៃថែទាំ

វិក្កយបត្រដើមនៃថ្លៃថែទាំដែលចេញដោយមន្ទីរពេទ្យឬក្រុមហ៊ុនផ្តល់សេវាថែទាំអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

អាស័យដ្ឋានប្រៃសណីយ៍នៃឯកសារទាមទារសំណង: 北京市西城区金融街 23 号平安大厦 9 层（邮编 100033）

អ្នកទទួល: 来华项目组

ទូរស័ព្ទ: 4008105119

**គ្រោងការណ៍នេះគឺជាការរួមបញ្ចូលគ្នានៃផលិតផលធានារ៉ាប់រង**

សម្រាប់ព័ត៌មានអំពីការធានារ៉ាប់រងចុងក្រោយនិងមាតិកាថ្មីៗសូមចូលទៅគេហទំព័រធានា រ៉ាប់រងក្រៅប្រទេស www.lxbx.net

ទំព័រពណ៌នេះគឺដើម្បីស្វែងយល់អំពីខ្លឹមសារនៃផលិតផល ការបកស្រាយចុងក្រោយនៃខ្លឹមសារខាងលើជាកម្មសិទ្ធិរបស់ ក្រុមហ៊ុនភីងអាន Insurance Company of China., LTD ។

ក្នុងករណីជំទាស់យកភាសាចិនជាគោល។